# កិច្ចប្រជុំក្រុមការងារផ្នែកកម្មន្តសាល សហគ្រាស ធុនតូច និងមធ្យម និងសេវា នៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ





កិច្ចប្រជុំក្រុមការងារផ្នែកកម្មន្តសាល សហគ្រាស ធុនតូច និងមធ្យម និងសេវា នៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ត្រូវបានប្រារព្ធធ្វើឡើង នៅព្រឹកថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ២០១៤ ក្រោមអធិបតីភាព ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាសហប្រធានជាមួយ លោកឧកញ៉ា **តែ តាំងប៉** ប្រធានសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា ដោយមានការចូលរួមពីសមាជិកក្រុមការងារស្ថិតក្នុងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល និងតំណាងវិស័យឯកជនយ៉ាងច្រើនកុះករ ។

មានប្រសាសន៍បើកកិច្ចប្រជុំ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានចាត់ទុកកិច្ចប្រជុំថ្ងៃនេះមានសារៈសំខាន់ ដើម្បីអនុវត្តឱ្យស្របនិងការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាល តាមសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ២០០៤ ។ ឯកឧត្តម បានកោតសរសើរ ចំពោះសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម ដែលបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការប្រមូលផ្តុំនូវសហគ្រាសធុនតូច និងមធ្យម ដើម្បីពង្រឹងជីវភាព និងរួមចំណែករៀបចំគោលនយោបាយជាមួយរាជរដ្ឋាភិបាល ក្នុងន័យឱ្យសហគ្រាសធុនតូច និងមធ្យម មានដំណើរទៅមុខកាន់តែឿនលឿន អាចមានលទ្ធភាពប្រកួតប្រជែង ក្នុងបរិបទនៃសហគមន៍សេដ្ឋកិច្ច អាស៊ាន នៅឆ្នាំ២០១៥ ខាងមុខ ។

លោកឧកញ៉ា **តែ តាំងប៉** ប្រធានសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា និងតំណាងវិស័យឯកជន ស្ថិតក្នុងសម្ព័ន្ធសមាគម សហគ្រាសធុនតូច និងមធ្យម បានអានកម្រងសំណួរ និងពិពណ៌នាអំពីបញ្ហា ដើម្បីឱ្យអង្គប្រជុំជួយដោះស្រាយ ដែលរួមមានចំនួន០៩បញ្ហាគឺ **ទី១:** ស្នើឱ្យក្រសួងបរិស្ថាន ពិនិត្យលើអនុក្រឹតលេខ ២០៩ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញដាប់ក៏រិតកំណត់ ដែលអនុក្រឹតនេះ បានហាមឃាត់ ការនាំចូលវត្ថុធាតុដើម ដូចជា: ចំនៀរដែក កំទេចដែកស្និត សំណបាហាំង រីដែកថែប ធ្វើឱ្យប៉ះពាល់ដល់សិប្បកម្ម ស្លដែក ដែលធ្វើឱ្យខ្វះវត្ថុធាតុដើមសម្រាប់ដំណើរការផលិតកម្ម **ទី២:** ការចំណាយខ្ពស់ពេកទៅលើការបំពេញបែបបទសម្រាប់ធ្វើការនាំចេញ ដោយស្នើឱ្យស្ថាប័នពាក់ព័ន្ធ ជួយកាត់បន្ថយបែបបទមួយចំនួន ដូចជា: Export Permit-Camcontrol Survey-Customs Processing Fee និងសុំឱ្យលប់ចោលតំលៃ Clearance Fee រីក៏អាចឱ្យក្រុមហ៊ុនធ្វើការ Clearance នៅមាត់ច្រកតែម្តង **ទី៣:** ការប្រកួតប្រជែងមិនស្មើភាព ដោយស្នើឱ្យក្រសួងពាណិជ្ជកម្មអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានកាំកុងត្រូល និង ប៉ូលីសសេដ្ឋកិច្ច ពិនិត្យនិងរិតបន្តឹងការនាំចូលទំនិញ ដែលមិនបង់ពន្ធនាំចូល បង់អាករលើតម្លៃបន្ថែម ហើយទំនិញខ្លះទៀតមិនមានគុណភាពសមស្រប ដែលធ្វើឱ្យប៉ាពាល់ដល់សិបកម្មក្នុងស្រុក ដែលបានអនុវត្តតាមច្បាប់ត្រឹមត្រូវ **ទី៤:** ការចុះអធិការកិច្ចត្រួតគ្នា ដោយបានស្នើឱ្យក្រសួងស្ថាប័នទាំងអស់អនុវត្តតាមសេចក្តីប្រកាសអន្តរក្រសួងលេខ: ៨៦៨ ឧរថ.ប្រក ចុះថ្ងៃទី២២ ខែ តុលា ឆ្នាំ២០១០ ស្តីពីការអនុវត្ត និងការរៀបចំសម្របសម្រួលស្ថាប័នមានសមត្ថកិច្ច នៃប្រព័ន្ធគ្រប់គ្រងម្ហូបអាហារចាប់តាំងពីកសិដ្ឋានផលិត ដល់តុបរិភោគ ។ ចំណុចនេះវិស័យឯកជន ស្នើដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បង្កើតក្រុមការងារពិសេសមួយ ជួយដល់សហគ្រាសធុនតូច និងមធ្យម នៅពេលមានការរំខានផ្សេងៗ **ទី៥:** ប្រកាសថ្មីស្តីពី "នីតិវិធីសម្រាប់ការចេញ កែសម្រួល បន្ត ព្យួរ និងដកហូតប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត" ដោយស្នើឱ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម មេត្តាឆ្លើយតប និងផ្តល់សេចក្តីណែនាំដល់អ្នកបានដាក់ពាក្យស្នើសុំប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មទឹកស្អាត ដែលបានទទួលការយល់ព្រមពីអាជ្ញាធរមូលដ្ឋាន និងបានដាក់ជូនក្រសួងនូវឯកសារតម្រូវផ្សេងៗ មុនពេលប្រកាសស្តីពី "នីតិវិធីសម្រាប់ការចេញ កែសម្រួល បន្ត ព្យួរ និងដកហូតប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ចូលជាធរមាន និងស្នើឱ្យក្រសួង កំណត់ និងផ្សព្វផ្សាយពីរូបមន្តនៃការគណនាតម្លៃទឹកលក់ ។ សូមឱ្យការកំណត់រូបមន្តគណនា តម្លៃទឹកលក់នេះ មានរួមបញ្ចូលពីចំណាយការប្រាក់នៃកំចីទុនវិនិយោគចំណាយជាក់ស្តែង ចំណាយលើការខូចខាតបណ្តាញចែកចាយទឹក និងមានទុកប្រាក់ចំណេញសមស្រប និងជាពិសេសសូមឱ្យមានការចូលរួមពីអ្នកផ្គត់ផ្គង់ទឹកស្អាត ឯកជន ក្នុងការកំណត់រូបមន្តគណនាតម្លៃទឹកលក់ ។ **ទី៦:** ការជួសជុលផ្លូវ ដែលប៉ះពាល់ដល់

ប្រព័ន្ធចែកចាយទឹកស្អាត ដោយបានស្នើឱ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម កោះប្រជុំក្រសួងពាក់ព័ន្ធ និងភាគីពាក់ព័ន្ធ ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយ ដើម្បីបញ្ចៀសបញ្ហា រឺកាត់បន្ថយការខូចខាតលើបណ្តាញទឹកស្អាតក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត និងសុំឱ្យក្រុមហ៊ុន រឺគម្រោងអភិវឌ្ឍន៍ផ្លូវលំ និងផ្លូវជាតិ ធ្វើការទូទាត់សងនូវការខូចខាតបណ្តាញទឹកស្អាត ។ **ទី៧:** នាឡិការអាន រឺកុងទ័រភ្លើងដើរលឿនខុសប្រក្រតី ។ **ទី៨:** វិស័យភស្តុភា (Logistic) ដោយស្នើឱ្យរាជរដ្ឋាភិបាល សម្រួលលើការបំពាក់ឧបករណ៍លើស្ថានីយ៍ផ្លូវរថភ្លើង ។ ស្នើឱ្យវិស័យរថភ្លើងពង្រឹងទំនើបកម្មឧបករណ៍ និងសេវាកម្មរបស់ខ្លួនដល់អតិថិជន ។ **ទី៩:** ថ្លៃដឹកជញ្ជូនខ្ពស់ពេក ដោយតម្លៃដឹកជញ្ជូននៅប្រទេសកម្ពុជា មានតម្លៃខ្ពស់ជាងប្រទេសជិតខាង ប្រហែលជាបីដង គឺយើងដឹកជញ្ជូនក្នុងមួយតោន ចំណាយប្រហែល ១៥ ដុល្លា ខណៈដែលគេចំណាយត្រឹម ៥ ដុល្លារ ក្នុងចំងាយផ្លូវប្រហាក់ប្រហែលគ្នា ។ ការដឹកជញ្ជូន មានតម្លៃថ្លៃ ដោយសាស្ថានភាពផ្លូវយើង មិនល្អ និងតម្លៃប្រេងឥន្ធនៈ យើងថ្លៃជាងគេ ។

ជាកិច្ចដំណើរការនៃអង្គប្រជុំ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានអញ្ជើញធ្វើជាអ្នកសម្របសម្រួល ដោយលើកយកបញ្ហានីមួយៗខាងលើ មកដោះស្រាយជាក់ស្តែង តាមសមត្ថកិច្ចនៃស្ថាប័នពាក់ព័ន្ធរៀងៗខ្លួន ។

ចំពោះ **បញ្ហាទី១:** ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្រេចនឹងស្នើសុំទៅសម្តេចតេជោនាយករដ្ឋមន្ត្រី ដើម្បីកែសម្រួលអនុក្រឹតលេខ២០៩ ដើម្បីឱ្យមានការនាំចូលវត្ថុធាតុដើមដូចជាៈ ចំនៀរដែក កំទេចដែកស្និត ដែកថែបមិនច្រេះ កំទេចលោហៈដែកស្និត សំណបាហាំង រឺដែកថែប ដើម្បីអនុញ្ញាតឱ្យសិប្បកម្មស្លដែកមានលទ្ធភាពប្រើវត្ថុធាតុដើមទាំងនោះ ក្នុងផលិតកម្មរបស់ពួកគេ ដោយចាត់ទុកថា កំទេចដែកទាំងនោះមិនមែនជាកាកសំណល់ រឺកាកសម្រាម ដែលស្ថិតនៅក្នុងបញ្ជីទំនិញហាមឃាត់ទេ ។ **បញ្ហាទី២:** ទាក់ទងការចំណាយខ្ពស់ពេកទៅលើការបំពេញបែបបទ សម្រាប់ធ្វើការនាំចេញ ដោយស្នើសុំឱ្យក្រសួងកាត់បន្ថយ និងលុបចោលបែបបទមួយចំនួន តំណាងក្រុមការងារអន្តរក្រសួងបានធ្វើការឆ្លើយបំភ្លឺ និងលើកហេតុផល ដោយខានបញ្ជាក់ថាៈ រដ្ឋមិនអាចលុបបំបាត់របបត្រួតពិនិត្យបានឡើយ ពីព្រោះបាត់គោលការណ៍បីគឺ: ១ –ភាពអនុលោម ២–ភាពមិនក្លែងបន្លំ–៣ –រក្សាប្រទេសដើមកំណើត ។ ប៉ុន្តែ ស្នើឱ្យវិស័យឯកជនលើកឡើងពីតម្លៃចំណាយជាក់ស្តែង និងចំណាយក្រោមតុ តើទាក់ទងជាមួយស្ថាប័នណាខ្លះ? ដើម្បីក្រុមការងារពិនិត្យ និងដោះស្រាយជាក់ស្តែង រឺក៏អាចកាត់បន្ថយកំរៃសេវាណាមួយ ។ **បញ្ហាទី៣:** ការប្រកួតប្រជែងមិនស្មើភាពគ្នា តំណាងស្ថាប័ន ជំនាញបានឡើងបកស្រាយ ដោយបានបង្ហាញនូវការខិតខំរបស់ខ្លួនទាក់ទងនិងរបបត្រួតពិនិត្យទំនិញនាំចូល ដូចជាៈ ជីកសិកម្ម និងថ្នាំសម្លាប់សត្វល្អិតជាដើម ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ និងអ្នកធ្វើអាជីវកម្មស្របច្បាប់ក្នុងស្រុក ហើយក៏បានស្នើឱ្យមានការសហការគ្នាទាំងស្ថាប័នរដ្ឋ អាជីវករស្របច្បាប់ និងប្រជាពលរដ្ឋផងដែរ ។ **បញ្ហាទី៤:** ការចុះអធិការកិច្ចត្រួតគ្នា ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានលើកឡើងការខិតខំរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលឯកឧត្តម បានបង្កើតក្រុមការងារចម្រុះរបស់ក្រសួង ដោយសហការជាមួយអជ្ញាធរមូលដ្ឋានចុះពិនិត្យទីតាំងរោងចក្រ និងសិប្បកម្ម ។ ការចុះធ្វើអធិការកិច្ចនោះ គឺក្រសួងដើម្បីត្រួតពិនិត្យពីច្បាប់ទម្លាប់ អប់រំ ណែនាំ មិនមែនជាការចុះដើម្បីរំខាននោះទេ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានស្នើឱ្យស្ថាប័នពាក់ព័ន្ធត្រួតពិនិត្យឡើងវិញនូវកំលាំងសមត្ថកិច្ចរបស់ខ្លួនជៀសវាងការរំខានដល់វិស័យឯកជន។ ឯកឧត្តម បានពន្យល់ដល់វិស័យឯកជនដោយឧទាហរណ៍ថាៈ បើកសិផលនៅលើវាលស្រែ ជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម ពេលដល់រោងចក្រ សិប្បកម្ម ជាសមត្ថកិច្ចត្រួតពិនិត្យរបស់ក្រសួងឧស្សាហកម្ម

និងសិប្បកម្ម ពេលទំនិញលក់នៅលើទីផ្សារ ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម ។ រីឯ ប៉ូលីសសេដ្ឋកិច្ចធ្វើកិច្ចការទាក់ទង និងការធ្វើវិច្ឆេទកម្មសេដ្ឋកិច្ចប៉ុណ្ណោះ ។ **បញ្ហាទី៥ :** ប្រកាសថ្មីស្ដីពី "នីតិវិធីសម្រាប់ការចេញ កែសម្រួល បន្ត ព្យួរ និង ដកហូតប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មទឹកស្អាត និងស្នើឱ្យក្រសួង កំណត់និងផ្សព្វផ្សាយពីរូបមន្តនៃការគណនាតម្លៃ ទឹកលក់នោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានលើកឡើងផលប្រយោជន៍ នៃប្រកាសថ្មីនេះ ដែលផ្ដល់លទ្ធភាព ឱ្យអាជីវករទឹកស្អាត ទទួលអជ្ញាប័ណ្ណ ធ្វើអាជីវកម្មទឹកស្អាតរហូតដល់ ២០ឆ្នាំ ដែលនឹងជួយដល់ផែនការអភិវឌ្ឍន៍របស់ ពួកគេ និងអាចអនុវត្តខានតាមគោលការណ៍របស់ក្រសួង ហើយអ្វីដែលមានភាពស្មុគស្មាញ អាជីវករទឹកស្អាតអាចលើក ឡើងបន្ថែមក្នុងសិក្ខាសាលា ស្ដីពីអាជីវកម្មទឹកស្អាត នៅពាក់កណ្ដាលខែវិច្ឆិកា ខាងមុខ ដែលមានអាជីវករទឹកស្អាតទូទាំង ប្រទេសចូលរួម ។ ទាក់ទងនិងរូបមន្តគណនា ថ្លៃលក់ទឹក ក៏ដូចជាការគណនាទឹកបាត់បង់ ត្រូវបានការធ្វើបទឧទ្ទេសនាម ពីឯកឧត្តម ឯក សុនចាន់ រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។ **បញ្ហាទី៦:** ការជួសជុលផ្លូវ ដែលប៉ះ ពាល់ដល់ប្រព័ន្ធចែកចាយទឹកស្អាត ។ ចំណុចនេះ តំណាងក្រសួង ឧស្សាហកម្ម និងសិប្បកម្ម បានស្នើឱ្យអាជីវករទឹកស្អាត មុនតបណ្ដាញត្រូវមានការយល់ដឹងថាៈ តើការតបណ្ដាញទឹកត្រូវមានគម្លាតពីអ័ក្សផ្លូវប៉ុន្មានម៉ែត្រ? ហើយគួរដាក់ទីតាំងណា សមស្របជាង ហើយត្រូវដាក់វត្ថុចំណាំ ដើម្បីឱ្យអ្នកជីកការដ្ឋានផ្លូវថ្នល់ខានដឹងជាមុន ថាមានបំពង់បណ្ដាញទឹកនៅខាង ក្រោម ។ បញ្ហាទី៧: នាឡិការអាន រឺកុងទ័រភ្លើងដើរលឿនខុសប្រក្រតី តំណាងក្រសួងរ៉ែ និង ថាមពល បានស្នើ ឱ្យប្ដឹងតាមរយៈមន្ទីរ ខេត្ត ក្រុង ដើម្បីបញ្ជូនជំនាញទៅធ្វើការវាស់វែង រឺធ្វើឮ្យាសកម្មឡើងវិញ ។ រីឯ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ក៏បានជម្រាបថាៈ ក្រសួងមានវិទ្យាស្ថានស្តង់ដារជាតិ និងវិទ្យាស្ថានមាត្រាសាស្ត្រ ដែលអាច ធ្វើកិច្ចការនេះបានដែរ បើមានតម្រូវការ ។ **បញ្ហាទី៨:** បញ្ហាភស្តុភា ដែលស្នើឱ្យបំពាក់ទំនើបកម្មឧបករណ៍សម្រាប់ត្រួត ពិនិត្យវិស័យដឹកជញ្ជូនតាមរថភ្លើង តំណាងក្រសួងសាធារណការ បានបញ្ជាក់ថាៈ ក្រុមហ៊ុនរថភ្លើង បានបំពាក់ម៉ាស៊ីន Scan ចល័ត ហើយក៏បាននាំចូលក្បាលរថភ្លើង និងឧបករណ៍ផ្សេងៗមានតម្លៃទឹកប្រាក់ចំនួន៨០លានដុល្លាអាមេរិក ដើម្បី ទំនើបកម្ម និងពន្លឿនការងារត្រួតពិនិត្យ ហើយរាជរដ្ឋាភិបាលក៏កំពុងយកចិត្តទុកដាក់ ក្នុងការកសាង និងពង្រីកផ្លូវឱ្យមាន គុណភាពរឹងមាំផងដែរ ។ **បញ្ហាទី៩:** តម្លៃការដឹកជញ្ជូនខ្ពស់ពេក ។ បញ្ហានេះ អង្គប្រជុំខានទទួលស្គាល់ ពីព្រោះដោយសារ ស្ថានភាពផ្លូវ ប្រេងឥន្ធនៈនៅមានតម្លៃខ្ពស់ និងមានចំណាយទៅលើកុងត្រូលជជុះ និងក្រៅផ្លូវការមួយចំនួនផងដែរ ។ តែ បញ្ហានេះ ជាបញ្ហាដែលត្រូវរួមគ្នាដោះស្រាយ ហើយបញ្ហានេះកំពុងស្ថិតនៅក្នុងវិថីកំណែទម្រង់របស់រាជរដ្ឋាភិបាល ។ ម៉្យាងទៀតការអភិវឌ្ឍន៍វិស័យដឹកជញ្ជូនតាមរថភ្លើង ជាដំណោះស្រាយដ៏ប្រសើរមួយទៅថ្ងៃមុខ ។





